# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៥៥១ [illegible] កសក

## សេចក្តីសម្រេច

## ស្តីពី

## ការប្រគល់សិទ្ធិកាន់កាប់ដាយត្រី ដាយត្រីលេញ និងដាយបង្កង ជូនអតិថិជន ដែលដេញថ្លៃបានធ្វើអាជីវកម្មក្នុងអាណត្តិនេសាទ ឆ្នាំ២០១៥-២០១៦ និង ឆ្នាំឆ្នាំ២០១៦-២០១៧

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១០ ស្តីពីនីតិវិធីនៃការវិនិយោគការដេញថ្លៃជាសាធារណៈ ឬការជួលតាមការព្រមព្រៀង និងការបង់ថ្លៃឈ្នួលនេសាទ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

- បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១២ ស្តីពីការរំសាយឡូត៍នេសាទក្នុងខេត្តកណ្តាល កំពង់ចាម ព្រៃវែង និងតាកែវ និងរៀបចំជាកន្លែងអភិរក្សជលផល
- បានឃើញប្រកាសលេខ០០០៤០ ប្រក.កសក ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៨៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់នៃនាទីព្រៃលិចទឹក ឡូត៍នេសាទ និងកន្លែងបម្រុងទុកនៅទឹកសាប
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល ។

**សម្រេច**

**ប្រការ១.**_

ត្រូវបានប្រគល់សិទ្ធិកាន់កាប់ដាយត្រី ដាយត្រីលេញ និងដាយបង្កង ជូនអតិថិជនដែលដេញថ្លៃបានសម្រាប់ធ្វើអាជីវកម្មក្នុងរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រៃវែង ក្នុងអាណត្តិនេសាទ ឆ្នាំ២០១៥-២០១៦ និងឆ្នាំ២០១៦-២០១៧ ដូចមានរាយឈ្មោះនៅក្នុងតារាងឧបសម្ព័ន្ធដេញថ្លៃឈ្នួលដាយត្រី ដាយត្រីលេញ និងដាយបង្កង ភ្ជាប់មកជាមួយនេះ។

**ប្រការ២.**_

សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.**_

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម នាយអធិការដ្ឋានរដ្ឋបាលជលផលចតុមុខ នាយខណ្ឌរដ្ឋបាលជលផលពាក់ព័ន្ធ និងសាមីជនដែលមានឈ្មោះនៅក្នុងតារាងឧបសម្ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សាលារាជធានី-ខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

# តារាងឧបសម្ព័ន្ធ

ភ្ជាប់សេចក្តីសម្រេចលេខ......៥៤១......សសរ.កសក ចុះថ្ងៃទី.....២៧.....ខែ...កញ្ញា...ឆ្នាំ២០១៥ ស្តីពីការប្រគល់សិទ្ធិឲ្យអ្នកដេញថ្លៃឈ្នួលដាយត្រី ដាយត្រីលេញ និងដាយបង្កង បានកាន់កាប់ធ្វើអាជីវកម្មនេសាទ នៅក្នុងរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រៃវែង សម្រាប់អាណត្តិនេសាទឆ្នាំ២០១៥-២០១៦និងឆ្នាំ២០១៦-២០១៧។

ឯកតា : រៀល

| ល.រ | រាជធានី-ខេត្ត | ឈ្មោះអ្នកដេញថ្លៃបាន | ប្រភេទ និងលេខដាយត្រី | ថ្លៃដេញបាន | ផ្សេងៗ |
|---|---|---|---|---|---|
| **ក.រាជធានីភ្នំពេញ** | | | | | |
| | | | ដាយត្រី | | |
| ១ | | លោក ម៉ាន ហ្វា | ៣A | ២៥.១០០.០០០ | |
| ២ | | លោក វណ្ណ ប៊ុនថា | ៣B | ៣៤.៥០០.០០០ | |
| ៣ | | លោក ម៉ាត់ សារី | ៣D | ៤៧,២០០,០០០ | |
| ៤ | | លោក លី គួប | ៤B | ៥៧.០០០.០០០ | |
| ៥ | | លោក យោក ម៉ូសា | ៤C | ៦៧.១០០.០០០ | |
| ៦ | | អ្នកស្រី ឡេះ ម៉ារី | ៤D | ៦៧.០០០.០០០ | |
| ៧ | | លោក ម៉ូត ហូសាន់ | ៥B | ៥៧.១០០.០០០ | |
| ៨ | | អ្នកស្រី សេន ម៉ែស្មាស់ | ៥C | ៥៥.០០០.០០០ | |
| ៩ | | អ្នកស្រី ម៉ាត់ ហ្វាទីម៉ាស់ | ៥D | ៥៧.៥០០.០០០ | |
| ១០ | | លោក រ៉ស់ វ៉ានី | ៦C | ៣៤.៥០០.០០០ | |
| ១១ | | លោក លី យូសុះ | ៦D | ៣៥.១០០.០០០ | |
| | | **សរុប ក** | | ៥៣៧.១០០.០០០ | |
| **ខ.ខេត្តកណ្តាល** | | | | | |
| | | | ដាយត្រី | | |
| ១ | | លោក កាញ់ សុភ័ក្រ្ត | ១៥A | ២០.០០០.០០០ | |
| ២ | | លោក សៀវ វិរៈ | ១៥B | ៧៨.០០០.០០០ | |
| ៣ | | លោក សុខ សម្បត្តិ | ១៥C | ១៥៧.០០០.០០០ | |
| | | **សរុប ខ** | | ២៥៥.០០០.០០០ | |
| **គ.ខេត្តព្រៃវែង** | | | | | |
| | | ១ | ដាយត្រីលេញ | | |
| ១ | | លោក ចែម សុគន្ធ | លេខ១ | ៣០.០០០.០០០ | |
| ២ | | លោក លន់ វ៉ាឌី | លេខ៥ | ៣.៤០០.០០០ | |
| ៣ | | លោក កុយ សុភាព | លេខ៧ | ១២.០០០.០០០ | |
| | | សរុប ១ | | ៤៥.៤០០.០០០ | |
| | | ២ | ដាយបង្កង | | |
| ១ | | លោក ចិន ឡុង | ១A | ១០.០០០.០០០ | |

| | | | | | |
|---|---|---|---|---|---|
| ២ | | លោក ជ្រូក សាខន | ១C | ៦.៥០០.០០០ | |
| ៣ | | លោក ស វ៉េត | ១D | ៣.៥០០.០០០ | |
| ៤ | | កញ្ញា យឹម ចាន់ទី | ១E | ៦.៦០០.០០០ | |
| ៥ | | លោក ឡាយ រៀង | ១G | ២.៥០០.០០០ | |
| ៦ | | លោក ផេង កក្កដា | ១H | ៣.៥០០.០០០ | |
| ៧ | | លោក ប៊ុន ដារ៉េត | ១I | ១.៣០០.០០០ | |
| ៨ | | អ្នកស្រី ពិន ញាណ | ១J | ៣.០០០.០០០ | |
| ៩ | | លោក គង់ សារួន | ១K | ១.១០០.០០០ | |
| ១០ | | លោក ម៉ូវ ផាត | ១L | ១.១០០.០០០ | |
| ១១ | | លោក ជាល ពាក | ១M | ៧.០០០.០០០ | |
| | | សរុប ២ | | ៤៦.១០០.០០០ | |
| សរុប គ (១, ២) | | | | ៩១.៥០០.០០០ | |
| សរុបរួម (ក ខ គ) | | | | ៨៨៣.៦០០.០០០ | |

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**